This project is
co-funded by:

CNFSC reflect workshop minute

The workshop was organised from 11 – 12 Nov, 2011 in Svay Rieng province reflect particularly on Sustainable Agriculture work.

# កំណត់ហេតុ

ស្តីពីៈ ការឆ្លុះបញ្ចាំងពីលទ្ធផលផ្នែកសន្តិសុខស្បៀង របស់បណ្តាញអធិបតេយ្យភាពស្បៀង

ថ្ងៃទី ១១–១២ ខែ វិច្ឆការ ឆ្នាំ ២០១០ នៅផ្ទះសំណាក់ កាកបាទក្រហម ខេត្តស្វាយរៀង។ជាកិច្ចចាប់ផ្តើម

ក្រុមការងារអាត់សិនអេតបានរៀចំបើកកម្មវិធីសិក្ខាសាលាដោយលោកចេងវិរៈ និងស្វាគមន៍ដោយលោកជឹមសុផលប្រធានជាបណ្តាលសន្តិសុខស្បៀង ហើយបានធ្វើការណែនាំអោយស្គាល់អោយស្គាល់គ្នាតាមបណ្តាលខេត្តនីមួយៗទាំង១៦អង្គការបន្ទាប់មកមានការឡើងបង្ហាញរបាយការណ៍សមត្ថិផលសំខាន់ៗពីសកម្មភាពរបស់បណ្តាញរយៈពេល១ឆ្នាំរបស់អង្គការនីមួយៗក្នុងនេះមានការបង្ហាញតាមអង្គការ

–ការបង្ហាញរបស់អង្គការកូហ្វាប

១. ដំណើរការសកម្មភាព

–ក្រុមចិញ្ចឹមមាន់

–បណ្តុះបណ្តាលពីកាចេិញ្ចឹមមាន់បច្ចេកទេស

សំនួរ បញ្ហាកើតមាននៅកូហ្វាបលោក កែ វាន ការជួល ពន្ធ័ក្នុងការជំពាក់បំណុលគេ

ហើយមានការជួលពន្ធ័គ្រឿងចក្រច្រូតកាត់ ដោយលក់ គោក្របីចេញចោល

- ទី១ ជួលភ្ជួរ ជួលច្រូត ទិញជីគីមី ចំណាយច្រើនចំណូលតិច
- លោកវិឆ័យ បានមានប្រសាសន៍ឱ្យជួយវិភាគពីដំណាក់កាលបំណុលគេ

អង្គការអភិវឌ្ឍធនធានមនុស្សព្រះវិហា

–បញ្ហា : ច្បារបស់ពួកគាត់គាត់មិនដាំ គាត់ទៅដាំតាមមុំស្រែ

–បញ្ហាៈ ដំណាំរបស់ពួកគាត់រលួយ ងាប់

–ត្រី ចិញ្ចឹមអណ្តែងបាន ៣ស្រះ ត្រីនោះងាប់ហើយមិនធំ

–ចិញ្ចឹមជ្រូកបាន ១ក្បាលដោយមានជំងឺ ឈឺចិញ្ចឹមមិនកើត ធ្វើឱ្យបង្ខំចិត្តលក់ចោលដោយតំលៃថោក

សំនួរ

លោកវារៈ ធ្វើស្រែបាន៨.៥0 ហិតា ប.វ.ស ចំនួន៥ស្រែអង្គការ KABB សកម្មភាព សហគមន៍ពំទាន់មានភាពយល់ដឹងទៅលើសារៈប្រយោជន៍នៃការប្រើប្រាស់ជី

**ឧបសគ្គ**

១ លំបាកក្នុងការគៀងប្រជាជនប្រជុំ

២ជីវភាពគ្រួសារ ធ្លាក់ចុះ

៣ ការចំណាក់ស្រុក

៤ សិក្ខាកាមមួយចំនួនមិនចេះអក្សរ

៥ ខ្វះគ្រាបលពូជសំរាប់ដាំដុស

៦ ខ្វះគ្រាប់ពូជសំរាប់ធ្វើស្រែ

-មានទឹកភ្លៀងច្រើនពេកពិបាកធ្វើដំណើរទៅប្រជុំ

-ពិបាកគៀងគរ

-មួយចំនួនតូចមិនចេះអក្សរ

-ជួបបញ្ហាខ្វះទឹក ប្រភពទឹក

-ទឹកលិចពិបាកដាំដំណាំ

-ការដឹកនាំពំបានយល់ច្បាស់

-ពិបាក់ក្នុងការធ្វើជង្រុក

សំនួរ

-តើអង្គការ ឬ សហគមន៍បានរៀបចំក្រុមបានត្រឹមត្រូវឬនៅ ?

លោក ស៊ីវុត្ថា

១ លោកបាន ពន្យល់ ពីការចងក្រងក្រុម

ពន្យល់ពីការចង ធ្វើការចង់ចូលចិត្ត

ការពិនិត្យ លើដី មានសមត្ថភាព

និយាយពីចំមាន ៤ គឺ ចំពេល ចំណូល ចំណាយ ចំកន្លែង

-ពន្យល់ពីការរកទីផ្សារកុំឱ្យបាត់បង់ឱកាសពីដៃ

-ការដាំត្រូវមានពូជ មើលដី យើងត្រូវគិតពីប្រភេទពូជ ដែលត្រូវរដូវកាល

-រដូវកាល : ការលក់ស្រស់ ការចចារតំលៃ ការកែច្នៃ

-តើចង់រឺ មិនចង់ ? អាស្រ័យលើចិត្ត

លោក ចេង វីរៈ ធ្វើបទបង្ហាញ

ការផាស់ប្តូរ ដែលយើងចង់បាន

១ ទុនដាក់បញ្ចូល

២ សកម្មភាព

៣ លទ្ធផល

៤ លទ្ធផលរយៈពេលវែង

៥ ការផ្លាស់ប្តូរ

ក្នុងថ្ងៃនេះដែរអង្គការនិមួយៗបានបង្ហាញពីលទ្ធផលនិងបញ្ហាដែលជួបប្រទះតាមអង្គការនីមួយៗ

**សំនួរសំរាប់រៀបចំផែនការយុទ្ធសាស្ត្រសិទ្ធិទទួលបានស្បៀងអាហារ**

១ ក្នុងការងារសិទ្ធិទទួលបានស្បៀងអាហាររបស់យើងមានអ្វីខ្លះ សូមធ្វើការវិភាគ ។

ជាកិច្ចចាប់ផ្តើម នាថ្ងៃទី ១២ កញ្ញា ផុន រដ្ឋា បានធ្វើការសំរបសំរួល ទៅលើការធ្វើបទបង្ហាញ ពីលទ្ធផល ផ្នែកកសិកម្មរបស់ក្រុមកសិករគំរូរនៅតាមអង្គការ ចំនួន៨ ដែលជាអង្គការដៃគូរបស់ អង្គការអាក់សិនអេត ដែលបាន ជ្រើសរើស ក្រុមកសិករចំនួនលើកកន្លងមក ។ សំរាប់អង្គការ ដែលត្រូវធ្វើបទបង្ហាញមុនគេ គឺ អង្គការ COFAP មកពីខេត្តព្រៃវែង បង្ហាញដោយ លោក វ៉ែន រូន បុគ្គលិកកម្មវិធី ចំពោះខ្លឹមសារនៃបទបង្ហាញមានដូចខាងក្រោម :

**<u>១.១. សកម្មភាពចងក្រងក្រុមកសិករ</u>**

<u>ក.ក្រុមដំណាំ:</u> មាន០៩ក្រុម មានសមាជិកសរុបចំនួន១៣២ នាក់ ស្រី៨៩នាក់ ។

<u>ខ.ក្រុមស្រូវ ប.រ.ស:</u> មាន០៦ក្រុម មានសមាជិកសរុបចំនួន ៨៧នាក់ ស្រី៥៦នាក់ ។

<u>គ.ក្រុមផ្សិតអំបោះ :</u> មាន០៣ក្រុម មានសមាជិកសរុបចំនួន ៤៨នាក់ ស្រី០៣នាក់ ។

<u>៤.ក្រុមស្ត្រីចិញ្ចឹមមាន់:</u> មាន០៣ក្រុមមានសមាជិកសរុបចំនួន៤៦នាក់។

<u>សរុបមានសមាជិកចំនួន=</u>មាន២១ក្រុមស្មើរ៣១៣នាក់ស្រី១៩៤នាក់

១.<u>២សកម្មភាពបណ្តុះបណ្តាល:</u>

១.២១.ការបណ្តុះបណ្តាលធ្វើផ្សិតអំបោះ

បណ្តុះបណ្តាលដល់ក្រុមផ្សិតចំនួន០៣ក្រុមសមាជិកបាន៤៤នាក់ស្រី២២នាក់

(ការច្រកល្បាយអាចមឺរណាចូលថង់) (ផលផ្សិតក្រោយពេលបណ្តុបណ្តាល

**១.២២.ការបណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមមាន់ដល់ក្រុមស្ត្រី:**

ក្រុមកសិករគំរូបានបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមមាន់ដល់ក្រុមស្ត្រីចំនួន០៣ ក្រុមបន្ថែមទៀតមានសមាជិកសរុបចំនួន៤៥នាក់ស្រី៤៤នាក់។ដោយបណ្តុះបណ្តាល បច្ចេកទេសចិញ្ចឹមគោលការណ៍ធម្មជាតិ និង របៀបធ្វើវ៉ាក់សាំងមាន់ ។

**១.២៣.ការបណ្តុះបណ្តាលពីបច្ចេកទេសដាំដំណាំ**

ក្រុមកសិករគំរូបានបណ្តុះបណ្តាលបច្ចេកទេសដាំដំណាំដល់ក្រុមដំណាំ ០៩ក្រុម មានសមាជិកសរុបចំនួន១៣២នាក់ ស្រី៨៩នាក់ ។ ដោយ បណ្តុះបណ្តាលរបៀបធ្វើជីកំប៉ុស្តិ៍ទឹក–គោក របៀបរៀបចំដី ដោយ បង្រៀលើផ្នែកទ្រឹស្តី និង បានអនុវត្តផ្ទាល់ ។ )

**១.២៤.ការបណ្តុះបណ្តាលពីបច្ចេកទេសស្រូវប.វ.ស**

បុគ្គលិកកូហ្វាបបានបណ្តុះបណ្តាលបច្ចេកទេសធ្វើស្រូវ ប.វ.ស ដល់ក្រុម ស្រូវ ប.វ.ស ចំនួន៦ក្រុម (ភូមិព្រៃឆ្លូង ព្រៃនគរក្នុង ធ្លក ត្របែក កណ្តាល និងភូមិកូនពោធិ៍) មានសមាជិកសរុបចំនួន ៨៧នាក់ ស្រីចំនួន ៥៦នាក់ ។

១.២៥. ការបណ្តុះបណ្តាលពីការគ្រប់គ្រងចំណូល-ចំណាយដល់តំណាង ក្រុមកសិករ:

បុគ្គលិកកូហ្វាបបានបើកវគ្គបណ្តុះបណ្តាលមួយស្តីអំពី "ការគ្រប់គ្រងចំណូល និង ចំណាយ " ដល់តំណាងក្រុមទាំង១៦ភូមិ (ក្រុមដំណាំ ក្រុមស្រូវប្រពេល វប្បកម្មបែបធម្មជាតិ ក្រុមផ្សិត និង ក្រុមកសិករគំរូ ) មានអ្នកចូលរួមសរុប៣៧ នាក់ ស្រី២៩នាក់ ។

១.២៦.ការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំដល់តំណាងក្រុមកសិករ:

បុគ្គលិកកូហ្វាបបណ្តុះបណ្តាលភាពជាអ្នកដឹកនាំដល់តំណាងក្រុមទាំង១៦ភូមិ មានអ្នកចូលរួមសរុ២២នាក់ ស្រី១៨នាក់ ។

១.២៧. ការបណ្តុះបណ្តាលស្តីពី" ទីផ្សារបន្លែ ផ្លែឈើកសិករ"

អង្គការកូហ្វាបបានសហការជាមួយមន្ទីរកសិកម្មខេត្តព្រៃវែង បានរៀបចំវគ្គ បណ្តុះបណ្តាលមួយស្តី" ទីផ្សារបន្លែ ផ្លែឈើកសិករ" ដោយមានការចូលរួមពី តំណាងកសិករទាំង១៦ភូមិ សរុបចំនួន២១នាក់ ស្រី០៩នាក់ ។ ក្នុងវគ្គនេះដែរ គឺបានបណ្តុះបណ្តាលអំពី:

- **របៀបតភ្ជាប់បណ្តាទីផ្សារ**
- **.របៀបប្រើប្រាស់ ដើម្បីដឹងពីព័ត៌មានទីផ្សារ**
- **បច្ចេកវិទ្យាមុនពេល និងក្រោយពេលប្រមូលផល**
- **ចំណាត់ថ្នាក់ គុណភាព ការវិចខ្ចប់**
- **.ដឹកជញ្ជូន**

**១.៣.ការភ្ជាប់បណ្តាញ:**

១-ភ្ជាប់បណ្តាញសហគមន៍ដើម្បីអធិបតេយ្យ ស្បៀងនៅ កម្ពុជារបស់អង្គការ ដៃគូរអាកសិនអេត ។

២-ភ្ជាប់បណ្តាញអង្គការក្រៅរដ្ឋាភិបាលខេត្តព្រៃវែង និង អង្គការដែលធ្វើលើ កសិកម្មនៅខេត្តព្រៃវែងដែលឧបត្ថម្ភដោយអង្គការ ំ ជជ

៣.ភ្ជាប់បណ្តាញសន្តិសុខស្បៀងជាមួយបន្ទីរកសិកម្មខេត្តព្រៃវេង ដែលរៀបចំ ដោយអង្គការសេដាក់ និង អង្គការដែលធ្វើកសិកម្មនៅខេត្តព្រៃវេង ។

**១.៤.បញ្ហាដែលប្រឈមមុខ:**

១.គ្រោះរាំងស្ងួត

២.ប្រឡាយទឹករាក់ពេក

៣.ការប្រើប្រាស់ជីគីមីហួសប្រមាណ

៤.ឧបករណ៍កសិកម្មទំនើបដូចជា: ម៉ាស៊ីនច្រូត ម៉ាស៊ីនភ្ជួរ..... ជាដើម ។

៥.លំហូស្រូវចេញពីសហគមន៍ពេលកំពុង និង ក្រោយច្រូតកាត់រួច ។

៦-ការជីពាក់បំណុលរបស់សហគមន៍

## ១.៥.ផែនការទប់ទល់

១.ផព្វផ្សាយដំណាំអោយមានការដាំដុះដែលត្រូវការទឹកតិច និង ចិញ្ចឹមសត្វ បន្ថែម ។

២.ចូលរួមធ្វើសមាហរន្តកម្មផែនការ ជាមួយថ្នាក់ឃុំ-សង្កាត់ ថ្នាក់ស្រុក និង ថ្នាក់ខេត្ត ដោយជំរុញអោយផែនការប្រចាំឆ្នាំឃុំ-សង្កាត់អោយបញ្ចូលផែនការ ស្តារប្រឡាយជាផែនការអទិ្ទភាព ។

៣.ផ្សព្វផ្សាយអោយសហគមន៍កាត់បន្ថយជីគីមី និង លើកកំពស់ការផលិតជី កំប៉ុស្តិ៍ ។

៤.បង្កើតអោយមានសហករស្រូវ ។

៥-សិក្សាស្រាវជ្រាវ សិក្ខាសាលាជាមួយអជ្ញាធរ ផ្សព្វផ្សាយ ផលិតឯកសារ ករណីសិក្សាស្តីពីបំណុល ។

**+សំនួរ** លោក ពូ ហាន មកពីអង្គការ សេត ខេត្តក្រចេះ តើអង្គការ COFAP បានគាំទ្រអ្វីខ្លះ ទៅដល់ក្រុមកសិករទាំងនោះ ដូចជា គ្រាប់ពូជ ទុនជាដើម ? **ចំលើយ អង្គការ**COFAP មិបានគាំទ្រអ្វីទេ គឺគាំទ្រតែ បច្ចេកទេសមួយចំនួនតែប៉ុណ្ណោះ ។ សំនួរ លោក សាម៉េត មកពីអង្គការ HRND មកខេត្តសៀមរាប បានសួរថា នៅចំនុចតារាងចំណូលចំណាយ ខាងអង្គការបានបញ្ចូលកំលាំងពលកម្មរបស់គាត់ដែររឺទេ ? ចំលើយ តំណាងអង្គការ COFAP ជាទទៅ កសិករយើងមិនទាន់បានគិតទៅដល់កំលាំងពលកម្មនោះទេ ហើយខាងអង្គការយើងក៏មិនបាននាំពួកគាត់គិតទៅដល់រឿងហ្នឹងដែរ ពីព្រោះខ្លាចពួកគាត់បាក់ទឹកចិត្ត ។ បង ស្រី ណន បានបន្ថែម ថា : ការគិតពីកំលាំងពលកម្មនេះយើងគួរតែគិតដែរ ពីព្រោះដើម្បីឱ្យពួកគាត់ចេះវិភាគនូវ កំលាំងពលកម្មដែលពួកគាត់ ត្រូវចំណាយ។

–ការបង្ហាញបន្តក្រុមកសិករគំរូរបស់អង្គការសាមគ្គីចំពោះក្រុមកសិករនេះក្រុមទី២ ទើបនឹងចាប់ផ្តើមនៅក្នុងឆ្នាំពីពាន់ដប់មាន៤ នាក់មកពីរបួនភូមិសំរាប់លទ្ធផលដែលក្រុមកសិករបានធ្វើមានជូនភ្ជាប់ខាងក្រោម,,,,,,។ ដែលធ្វើបទបង្ហាញ ដោយលោក សឹម ហ៊ិន បុគ្គលិកកម្មវិធី បទបង្ហាញមានដូចខាងក្រោម :

- ផ្លាស់ប្តូរបទពិសោធន រវាងកសិករ និង កសិករដើម្បីលើកកំពស់ការអនុវត្ត កសិកម្ម និង ការចិញ្ចឹមជីវិតរបស់កសិករមានដីតូច ។

**សកម្មភាព**

- ការបង្កើតកសិករគំរូ – ននោង ១៤ គុម្ព
- ទស្សនះកិច្ចនៅកំពង់ធំ – ត្រឡាច ៦ គុម្ព

- ការផ្តល់យោបល់ – រំដេង ៥គុម្ព
- ការបំបែកកសិករ – រមៀត ៣ គុម្ព
- ការបណ្តុះបណ្តាលបច្ចេកទេស – ជីនាងវង ៤រង
- ការប្រជុំប្រចាំខែ – ជីរណា ៣ រង
- មាន់: ៤១ក្បាល – បណ្តុះផ្សិតចំបើង ១ រង
- សឹកគ្រៃ : ១៣៥គុម្ព – សំ ១ គុម្ព
- ល្ពុង: ៥0 – ក្រសាំងទាប ១ រង
- ប៉េងប៉ោះ ៣00 ដើម – ស្លឹកបាស ៧ គុម្ព
- ត្រសក់ ១១ រង
- ន្រោះ ៧ រង
- សណ្តែកគួរ ១២ រង
- ស្ពៃ ១0 រង

**កសិករបំបែក: ចំនួន២0 នាក់**

**ចំណាយរួម : ១,២៦១,៦00 រៀល**

**ចំណូលរួម : ៣,៦៩៧,៣00 រៀល**

<u>បញ្ហាប្រឈមមុខ</u>

- ចោរលួច
- រលួយគល់
- រួញស្លឹក
- ចៃរុំ
- ដង្កូវ និង ខ្យងាយរូ
- ដង្កូវស៊ីរូងដើម
- ខ្វះប្រភពទឹក
- ការចូលរួមរបស់សហគមនៅមានកំរិត
- ការសំរបសំរួលក្នុងការចែករំលែករបស់កសិករគំរូនៅមានកំរិត

ដំណោះស្រាយ

- ជាប់ដោយដៃ
- ប្រើថ្នាំធម្មជាតិ
- ឌុកចោល
- បាញ់ទឹកសាប៊ូ លាយទឹកបាញ់
- ប្រើអង្រ្គង

+ សំនួរ សំរាប់បទបង្ហាញរបស់អង្គការសាមគ្គី កញ្ញា មកពីអង្គការ **HOM** បានចូលរួមយោបល់ថា អង្គការសាមគ្គីជ្រើសរើស កសិករសុទ្ធតែស្រីយើងដឹងហើយថា បច្ចុប្បន្ននេះស្រ្តីកំពង់តែជួបទៅនឹងការងារច្រើននៅក្នុងគ្រួសារ ហើយបើយើងដាក់ការងារ កសិកម្មមួយមុខទៀតគឺពួកពិតជារវល់ណាស់។

បទបង្ហាញបន្ត គឺក្រុមកសិករគំរូ របស់អង្គការ MPC ស្រុកស្រែអំបិល ខេត្តកោះកុង ដែលបង្ហាញដោយ លោក ម៉េង ហាក់វិន្ស័យ ចំពោះខ្លឹមសារមានដូចតទៅ ....

អ្នកស្រី យិន សាម៉ាក់ មានអាយុ ៥៤ ឆ្នាំ ប្តីរបស់គាត់ឈ្មោះ យឿន អៀង អាយុ៥៥ មានកូន៤នាក់ ស្រី ១នាក់ និងមានប្អូនស្រីង្កើត១នាក់។ បច្ចុប្បន្នរស់នៅភូមិបឹងព្រាវ ឃុំបឹងព្រាវ ស្រុកស្រែអំបិល ខេត្តកោះកុង ។
គ្រួសាររបស់អ្នកស្រី យិន សាម៉ាក់ គឺជាគ្រួសារដែលមានជីវភាពក្រីក្រនៅភូមិបឹងព្រាវ ឃុំបឹងព្រាវ ស្រុកស្រែអំបិល ខេត្តកោះកុង ។

-ចំពោះការប្រកបមុខរបរចិញ្ចឹមជីវិតវិញគឺគ្រួសារគាត់ធ្វើស្រែ ដាំដំណាំ ចិញ្ចឹមសត្វ ប៉ុន្តែការដាំដំណាំសំរាប់តែផ្គត់ផ្គង់គ្រួសារ និងលក់បន្តិចបន្តួចប៉ុណ្ណោះ។

-នៅខែ មេសា ឆ្នាំ ២០១០ អង្គការមជ្ឈមណ្ឌលម្លប់ព្រហ្មវិហារធម៌ បានអញ្ជើញរូបគាត់មកចូលរួមរៀនពីបច្ចេកទេសកសិកម្មតាមគោលការណ៍ធម្មជាតិ និងធ្វើទស្សនៈកិច្ចសិក្សាពីបទពិសោធន៍ល្អៗពីក្រុមកសិករគំរូនៅ អង្គការ HOM ខេត្តកំពង់ធំ ។

-ក្រោយពីបានរៀនពីបច្ចេកទេសកសិកម្មរួចមកគាត់ចេះធ្វើបច្ចេកទេសកសិកម្មជាច្រើនរួមមាន ការរៀបចំចំការឱ្យទៅជាចំការពហុប្រយោជន៍ បច្ចេកទេសចិញ្ចឹមជន្លេន ចិញ្ចឹមមាន់ ជ្រូក ដាំបន្លែ ធ្វើជីកំប៉ុស្តិគោក ។

របៀបដាំបន្លែ និងការប្រើប្រាស់ជី

-ការធ្វើកសិកម្មរបស់គាត់គឺតាមបច្ចេកទេស និងប្រើប្រាស់ជីធម្មជាតិ គឺជីកំប៉ុស្តិដែលគាត់បានធ្វើរួច យកមកក្រាលលើរងដំណាំរបស់គាត់មុននឹងដាំ ។ បង្ហាញបន្ត គឺអង្គការ **MPC** ស្រុកស្រែអំបិលដែលបង្ហាញដោយលោក ម៉េង វិន័យ សំរាប់លទ្ធផលរបស់ក្រុមកសិករគំរូ ៤នាក់

លោក ជា សំណាង

លោក ជា សំណាង អាយុ ៤៦ ឆ្នាំ ប្រពន្ធរបស់គាត់ឈ្មោះព្រាប សុធឿន អាយុ២៥ឆ្នាំ មុខរបរលក់ដូរ ឥវ៉ាន់បន្តិចបន្តួចនៅនឹងផ្ទះ សព្វថ្ងៃគាត់មានកូន ២នាក់ ស្រី ១នាក់ គ្រួសាររបស់គាត់រស់នៅភូមិជ្រោយ ឃុំបឹងព្រាវ ស្រុកស្រែអំបិល ខេត្តកោះកុង

-គ្រួសាររបស់លោក ជា សំណាង គឺជាគ្រួសារក្រីក្របំផុតមួយក្នុងចំណោមគ្រួសារក្រីក្រជាច្រើនក្នុងភូមិជ្រោយ ឃុំបឹងព្រាវ ស្រុកស្រែអំបិល ខេត្តកោះកុង ។

-ចំពោះការប្រកបមុខរបរវិញគឺធ្វើស្រែ និងដាំបន្លែបន្តិចបន្តួចសំរាប់ផ្គត់ផ្គង់ជីវភាពក្នុងគ្រួសារ ប៉ុន្តែការផ្គត់ផ្គង់ជីវភាពគ្រួសារ នោះមិនបានគ្រប់គ្រាន់ទេ គឺពីមួយថ្ងៃទៅមួយថ្ងៃជីវភាពគ្រួសារកាន់តែពិបាកទៅពិបាកទៅ ធ្វើឱ្យគាត់រករបរអ្វីពិតប្រាកដពុំបាន។

-នៅខែ មេសា ឆ្នាំ ២០១០ អង្គការមជ្ឈមណ្ឌលម្លប់ព្រហ្មវិហារធម៌ បានអញ្ជើញរូបគាត់មកចូលរួមរៀនពីបច្ចេកទេសកសិកម្ម តាមគោលការណ៍ធម្មជាតិ និង ធ្វើទស្សនៈកិច្ចសិក្សាពីបទពិសោធន៍ល្អៗដែលក្រុមកសិករគំរូនៅ អង្គការ HOM នៅខេត្តកំពង់ធំ។

-ក្រោយពីបានរៀនពីបច្ចេកទេសកសិកម្មរួចមកគាត់បានចេះធ្វើបច្ចេកទេសកសិកម្មជាច្រើនរួមមាន បច្ចេកទេសធ្វើជីកំប៉ុស្តិ៍ទឹក ជីកំប៉ុស្តិ៍គោក វ៉ាក់សាំងមាន់តាមធម្មជាតិ ថ្នាំសំលាប់សត្វល្អិតធម្មជាតិ ចិញ្ចឹមមាន់ ចិញ្ចឹមជន្លេន ដាំបន្លែ ធ្វើស្រូវ ប.វ.ស ។

របៀបដាំបន្លែ និងការប្រើប្រាស់ជី

ការដាំបន្លែរបស់គាត់គឺប្រើជីធម្មជាតិដែលគាត់ធ្វើខ្លួន ឯង គឺគាត់យកជីកំប៉ុស្តិ៍គោកទៅក្រាលលើដីដែលដាំ ដំណាំ ជីកំប៉ុស្តិ៍ទឹកវិញគឺគាត់យកមកស្រោចលើដំណាំពេលកំពុងលូតលាស់ រីឯជីអ៊ីអឹមវិញគឺគាត់យកមក ស្រោចដំណាំ និងស្រោចផ្លើផ្កាចំពោះដំណាំយកផ្លែដើម្បីឱ្យផ្លែល្អហើយច្រើន ។ ចំពោះការដាំស្ពៃវិញ គឺគាត់ធ្វើការដាក់ជីដូចគ្នា ប៉ុន្តែគាត់ធ្វើស្បៃសំរាប់គ្របវា ដើម្បីឱ្យស្ពៃលូតលាស់កាន់តែល្អ ។ ឃើញថាការដាំដំណាំរបស់គាត់ពិតជាទទួលបានចំណូលនិងលើកស្ទួយជីវភាពគ្រួសារបានមួយកំរិតទៀត ។

ការចិញ្ចឹមមាន់ និងការផ្តល់ចំណី

ការចិញ្ចឹមមាន់គឺគាត់ចិញ្ចឹមតាមបច្ចេកទេសធម្មជាតិ និងមានទ្រុងត្រឹមត្រូវ ពេលកូនមាន់នៅតូចគឺគាត់ឱ្យស៊ីកណ្តៀ ដល់ពេលធំគាត់ ឱ្យស៊ីជន្លេន ដែល គាត់ចិញ្ចឹមដើម្បីធន់ជំងឺ និងឆាប់ធំ។ ចំពោះវ៉ាក់សាំងវិញគឺគាត់យកវ៉ាក់ សាំង ដែលគាត់បានធ្វើខ្លួនឯងរួចនោះយកមកបន្តក់ឱ្យមាន់ផឹក។ក្រោយពីធ្វើ វ៉ាក់សាំងចំពោះមាន់ រួចមកឃើញ ថា មាន់របស់គាត់មិនដែលចេះឈឺ និង ងាប់ទេទោះជាមាន់អ្នកនៅជិតខាងងាប់យ៉ាងណាក៏ដោយ ។

បច្ចេកទេសធ្វើជីសរីរាង្គ អ៊ី អ៊ិម ធម្មជាតិ

- ធាតុផ្សំ

| | |
|---|---|
| ស្ករត្នោត | ១.៣ គីឡូក្រាម |
| កន្ទក | ១ គីឡូក្រាម |
| ដីដំបូក | ១ គីឡូក្រាម |
| ទឹក | ២០ លីត |

- របៀបលាយ

រួចយកដីដំបូកនិងកន្ទក់មកលាយចូលគ្នារួចចាក់ទឹកស្ករល្មមសើមអាចពូតបាន រួចមកយកស្លឹកចេកខ្ចប់

ទើបយកមកត្រាំទឹកស្ករ

ដែលលាយរួច ទុកកុំឱ្យត្រូវពន្លឺរយៈពេល ២០ ថ្ងៃទើបអាចយកមកប្រើបាន ។

របៀបប្រើប្រាស់

យកទឹកជី១លីត លាយជាមួយទឹកធម្មតាចំនួន ២០០ លីត ស្រោចលើដំណាំ រៀងរាល់ថ្ងៃ ។

ការធ្វើស្រូវ ប.វ.ស តាមគោលការណ៍ធម្មជាតិ

ការធ្វើស្រូវ ប.វ.ស គឺគាត់ធ្វើស្រែតាមទំលាប់ ប៉ុន្តែ គាត់ស្ទូង តែមួយដើម និងការប្រើជីគឺគាត់ប្រើតែ ជីកំប៉ុស្តិ៍ដែលគាត់បានធ្វើតែប៉ុណ្ណោះ។

មិនត្រឹមតែធ្វើកសិកម្មដោយខ្លួនឯងនោះទេគឺគាត់បានចែករំលែកបទពិសោធន៍ទៅក្រុម បំបែកផ្សេងៗទៀតនៅក្នុងភូមិ ។

អ្នកស្រី សៀង ផេន

អ្នកស្រី សៀង ផេន អាយុ ៤០ឆ្នាំ ប្តីឈ្មោះ ប៉ុស ផន អាយុ ៤២ឆ្នាំ មានកូន ៥នាក់ ស្រី ៣នាក់ បច្ចុប្បន្នរស់នៅភូមិសារ៉ាយ ឃុំជ្រោយស្វាយ ស្រុកស្រែអំបិល ខេត្តកោះកុង ។

-គ្រួសាររបស់អ្នកស្រី សៀង ផេន គឺជាគ្រួសារក្រីក្រមួយក្នុងចំណោមគ្រួសារក្រីក្រជាច្រើនក្នុងភូមិសារ៉ាយ ឃុំជ្រោយស្វាយ ស្រុកស្រែអំបិល ខេត្តកោះកុង ។

-ចំពោះមុខរបរចិញ្ចឹមជីវិតវិញ គឺគ្រួសារគាត់ធ្វើស្រែ ចិញ្ចឹមសត្វ ដាំដំណាំ ប៉ុន្តែការប្រកបមុខរបរនេះសំរាប់តែផ្គត់ផ្គង់ក្នុងគ្រួសារតែប៉ុណ្ណោះ ។

-នៅខែ មេសា ឆ្នាំ ២០១០ អង្គការមជ្ឈមណ្ឌលម្លប់ព្រហ្មវិហារធម៌ បានអញ្ជើញរូបគាត់មកចូលរួមរៀនពីបច្ចេកទេសកសិកម្មតាមគោលការណ៍ធម្មជាតិ និង ធ្វើទស្សនៈកិច្ចសិក្សាពីបទពិសោធន៍ល្អៗពីក្រុមកសិករគំរូនៅ អង្គការ ឿ ខេត្តកំពង់ធំ។

-ក្រោយពីបានរៀនពីបច្ចេកទេសកសិកម្មរួចមកគាត់ចេះធ្វើបច្ចេកទេសកសិកម្មជាច្រើនរួមមាន ការរៀបចំដីភូមិរបស់គាត់ឱ្យទៅជាចំការពហុប្រយោជន៍ ចិញ្ចឹមមាន់ ជ្រូក ដាំបន្លែ ធ្វើជីកំប៉ុស្តិ៍គោក ជីកំប៉ុស្តិ៍ទឹក ។

-ការធ្វើកសិកម្មរបស់គាត់គឺតាមបច្ចេកទេស និង ប្រើប្រាស់ជីធម្មជាតិ គឺជីកំប៉ុស្តិ៍ដែលគាត់បានធ្វើរួច យកមកក្រាលលើរង ដំណាំ របស់គាត់មុននឹងដាំ បន្ទាប់មកគាត់យកជីកំប៉ុស្តិ៍ទឹកលាយជាមួយទឹកធម្មតារួចស្រោចលើដំណាំ។

ការដាំដំណាំរបស់គាត់រួមមាន សណ្តែកគួ ប៉េងប៉ោះ ត្រឡាច ននោង បន្លែភ្លៅកង្កែម លុង ក្រូចឆ្មារ ម្ទេស ត្រប់ កញ្ឆែត .... ឃើញ ថាការ ដាំរបស់ គាត់ពិត ជា ទទួលបានចំណូលក្នុងគ្រួសារ និងលើកស្ទួយជីវភាពគ្រួសារ ។

– ការធ្វើស្រូវ ប.រ.ស គឺគាត់ធ្វើតាមទំលាប់ ប៉ុន្តែគាត់ស្ទូងចាប់តែមួយដើម និងប្រើប្រាស់ជីគីមីខ្លះ។ ឃើញថាស្រូវ ប.រ.សរបស់គាត់គឺទទួលបានផលជាងស្រូវស្ទូងធម្មតា ។

**លោក ប៊ុន ខុន**

**លោក ប៊ុន ខុន អាយុ ៤៨ ឆ្នាំ ប្រពន្ធឈ្មោះ អន សុខគា អាយុ ៤៥ មានកូនចំនួន ៥នាក់ ស្រី១នាក់ (មាន** គ្រួសារ១នាក់ប្រុស)បច្ចុប្បន្នរស់នៅភូមិជ្រោយ ឃុំបឹងព្រាវ ស្រុកស្រែអំបិល ខេត្តកោះកុង ។

– ចំពោះមុខរបរគឺគាត់ធ្វើស្រែ និងចិញ្ចឹមមាន់ ជ្រូក ប៉ុន្តែការចិញ្ចឹមមាន់របស់គាត់មិនមានលក្ខណៈបច្ចេកទេសទេ គឺគាត់ចិញ្ចឹមតាមទំនៀមទំលាប់របស់គាត់ ។

បច្ចេកទេសចិញ្ចឹមត្រីអណ្តែង

–របៀបចិញ្ចឹមត្រីអណ្តែងគឺចិញ្ចឹមតាមបច្ចេកទេសធម្មជាតិ

–របៀបចិញ្ចឹមរបស់គាត់ គឺ ជីកស្រះទំហំ ៦ ម ឃ ៨ ម

– ដាក់អាចម៍គោ និង ទន្រានខែត្រ ដើម្បីបង្កើតបួងតុងសំរាប់ជាចំណីត្រី

– ពេលឃើញមានបួងតុងគ្រប់គ្រាន់គាត់ចាប់ផ្តើមយកកូនត្រីអណ្តែងមកលែង ចំនួន១៣០០ក្បាល ងាប់ប្រមាណជា៣០០ក្បាល សល់ប្រមាណជា១០០០ក្បាល ។

– ការផ្តល់ចំណីឱ្យស៊ីគឺគាត់ឱ្យស៊ីកណ្តៀ និងបាយលាយកន្ទកទៀងទាត់ពេលវេលា

–នៅខែ មេសា ឆ្នាំ ២០១០ អង្គការមជ្ឈមណ្ឌលម្លប់ព្រហ្មវិហារធម៌ បានអញ្ជើញរូបគាត់មកចូលរួមរៀនពីបច្ចេកទេសកសិកម្មតាមគោលការណ៍ធម្មជាតិ និង ធ្វើទស្សនៈកិច្ចសិក្សាពីបទពិសោធន៍ល្អៗពីក្រុមកសិករគំរូនៅ អង្គការ HOM ខេត្តកំពង់ធំ ។

–ក្រោយពីបានរៀនពីបច្ចេកទេសធ្វើកសិកម្មរួចមកគាត់បានចេះធ្វើដូចជា បច្ចេកទេសចិញ្ចឹមមាន់ បច្ចេកទេសចិញ្ចឹមត្រីអណ្តែង ។

របៀបដាំបន្លែប៉ាក់យូណាម

របៀបដាំបន្លែភ្លៅកង្កែប គឺគាត់ដាំតាមធម្មតា ទំហំដី ៣ឃ២ម

ចំណូលពីបន្លែនេះប្រមាណជា៦០,០០០រៀល កាត់លក់ម្តង (១០–១៥ ថ្ងៃ) ហើយងាយស្រួលលក់ក្នុងទីផ្សារ

## ការខារវេទ្រម្ម

- ប្រជុំប្រចាំខែ

- ធ្វើការតាមដាននិងឆ្លុះបញ្ចាំងសមាជិកក្រុម លើការអនុវត្តន៍កសិកម្ម
- ផ្សព្វផ្សាយបច្ចេកទេសកសិកម្មទៅដល់ក្រុមបំបែករបស់ខ្លួន

**សំនួរចំលើយ**

**កិច្ចបន្ត ការធ្វើបទបង្ហាញរបស់អង្គការ** HOM ដែលបង្ហាញដោយ លោកស្រី ស៊ិន ស៊ីណន បុគ្គលិកផ្នែកកសិកម្ម របស់អង្គការ HOM ខេត្តកំពង់ធំ ដែលរៀបរាន់ជូនខាងក្រោម :

ក្រោយពីកសិករ ៤នាក់បានទៅទស្សនៈកិច្ចសិក្សា នៅខេត្តកំពតមក ពួកគាត់បានពង្រីកកសិករ លើ៩១៦ភូមិ ហើយយកបទពិសោធន៍មកអនុវត្តន៍ បានលទ្ធផលលើដំណាំបាន ២២មុខ និងសត្វមាន់.ទា.ជ្រូក ត្រី.ជន្លេនក្រហម. ធ្វើជីកំប៉ុស្តិ៍គោក ទឹក. ថ្នាំបំផ្លាញ់សត្វល្អិត ថ្នាំបន្តក់មាន់.ធ្វើធនាគារស្រូវបាន២ភូមិ. បង្កើតក្រុមសន្សំប្រាក់បាន១ ក្រុមមានសមាជិក៥នាក់. ទទួលផែនការទស្សនៈកិច្ចសិក្សាពីអង្គការផ្សេងៗបានចំនួន១៣ លើក.ក្នុងនោះអង្គការដៃគូ៩អង្គការ. អង្គការមិនមានដៃគូ៤អង្គការ ដៃគូ៤អង្គការ ។

**កសិករគំរូ ឈ្មោះ សុខ រឿន** : បានទៅទស្សនៈកិច្ចសិក្សា នៅហាណូយ ប្រទេសវៀតណាម បាន១ លើក.កសិករគំរូ៤នាក់ បានបើក វគ្គបណ្តុះបណ្តាលពីបច្ចេកទេសកសិកម្មបាន៤លើក និង ប្រជុំឆ្លុះបញ្ចាំងដល់ក្រុមកសិករពង្រីក ២លើក លើ ១៦ភូមិ និង ចុះតាមដាន ចែករំលែកបទពិសោធន៍ ដល់អង្គការដៃគូ ពីបច្ចេកទេសកសិកម្ម បាន៩លើក លើ៥អង្គការ ។ អង្គការ គាំពារគ្រាប់ពូជ ហើយពួកគាត់យល់ពីរដូវកាលក្នុងការដាំដំណាំ នៅរដូវប្រាំងដាំលើដី នៅរដូវវស្សា ដាំដោយលើក រង ឱ្យខ្ពស់ ឬ លើករាន ដាំលើដបទឹកសុទ្ធ

ការវិភាគសេដ្ឋកិច្ច

- ដំណាំ បានចំណូល =៦.៥០០.៥០០៛ ចំណាយអស់ = ១.៨០០.២០០៛ ចំណាយលើកំលាំងពលកម្មអស់=៧៧៨.៥០០៛
- ជន្លេនក្រហម ចំណូលបាន =៤៧០.០០០៛ ចំណាយលើថង់ប្លាស្ទិចអស់=៨០០.០០០៛
- ត្រី ៥ស្រះ ចំណូលបាន=១.០៧០.០០០៛ ចំណាយថង់ប្លាស្ទិច ២០ម =១០០.០០០៛ ចំណាយលើកំលាំពលកម្ម ២០០.០០០៛
- ចិញ្ចឹមមាន់ ចំណូលបាន= ២.៧៥២.៥០០៛ ចំណាយពូជមាន់អស់ ៤០៧.៥០០៛ ចំណាយលើឈើធ្វើទ្រុង ២៧៨.៥០០៛
- ចិញ្ចឹមជ្រូក ចំណូលបាន ១.៥៧៥.០០០៛ ចំណាយទិញកូន អស់៧៥០.០០០៛ ចំណាយធ្វើទ្រុងអស់ ៨០៧.៥០០៛

សរុបចំណេញទាំងអស់= ២.៤៧៣.៨០០៛ ។

**សំនួរ ចំលើយ** –យោបល់ចូលរួម លោក ស៊ីវត្ថ បានមានស្រាសន៍ថា តាមអង្គការនីមួយៗពូកែថតរូប ជាពិសេសថតដំណាំ ពេល ខែ វស្សា នៅកន្លែង

ណាក៏ខៀវបំព្រងដែរ បើចង់ដឹងឧស្សា ឬ ខ្ជិល ទៅថតរូបអំឡុងពេលខែ ០២— ០៣ ទើបដឹងថាឧស្សាពិតប្រាកដរឺ អត់។

សំរាប់បញ្ហារបស់ក្រុមកសិករគំរូអង្គការ MPC

–មានសត្វល្អិតបំផ្លាញ

**បទបង្ហាញបន្តទៀត គឺ ក្រុមកសិករនៅអង្គការ មិត្តអភិវឌ្ឍន៍ជនបទ** RFDC ស្រុកក្រគរ ខេត្តពោធិសាត់ ដែលធ្វើបទបង្ហាញ ដោយលោក អុត ឡុង សំរាប់ខ្លឹមសារនិងលទ្ធផល មានដូចខាងក្រោម :

- ប្រជុំក្រុមធំរៀបចំផែនការ និងគូផែនទីស្រមើលស្រមៃ នៅអង្គការសាមគ្គី ខេត្តកំពង់ចាម ពីថ្ងៃទី២៧-២៨ ខែ០៤/២០១០
- បើកវគ្គបណ្តុះបណ្តាលពីបច្ចេកទេសធ្វើជីកំប៉ុស
- ទស្សនៈកិច្ចសិក្សានៅខេត្តកំពង់ធំ
- ការចុះតាមដានរបស់ក្រុមស្នូល បណ្តាញអធិបតេយ្យភាពស្បៀង
- ការប្រជុំតាមដានរបស់អង្គការប្រចាំខែ

តារាងមុខដំណាំ និង ចំណូលសំរាប់ក្រុមកសិករ ចំនួន៤នាក់

| ល-រ | មុខដំណាំ | សរុបចំនួនចាប់ពីខែ៥១០/២០១០ | ចំណូល. បញ្ហា<br>ដំណោះស្រាយ. ការរក្សាពូជទុក |
|---|---|---|---|
| ០១ | ត្រកួន | ២៦ រង | **<u>ចំណូលៈ</u>** |
| ០២ | សណ្តែកគួរ | ២៦ រង | -លក់បន្លែ =៥៧ម៉ឺន |
| ០៣ | ផ្ទី | ៧រង | -លក់មាន់បាន =៥៣ ម៉ឺន |
| ០៤ | ខ្ទឹ | ២រង | -លក់ជ្រូក =៨០ ម៉ឺន |
| ០៥ | ម្រះ | ៩ទ្រើង | -ស្រូវ ២១៣គីឡូ x ៩២០៛=១៩៥.៩០០៛ |
| ០៦ | ត្រលាច | ៨ទ្រើង | **<u>ចំណាយ</u>** |
| ០៧ | ដំឡូងមី | ៥០គីឡូ | -សរុប ៤៤៤.០០០៛ |
| | ស្លឹកគ្រៃ | ១៨៤គុម | -សងបាន ២៨០.០០០៛ |
| | ដំឡូងជ្វា | ១៣ រង | -នៅសល់ ១៦៤.០០០៛ |
| | ជីគ្រប់មុខ | ១៧រង | + **<u>បញ្ហាជួបប្រទះ</u>** |
| | ត្រប់វែង | ២៩រង | -មិនចេះពីវិធីទុកពូជ |
| | ននោង | ២១ ទ្រើង | -ទឹកប្រើមិនកើត មានជាតិកំបោរ និង |
| | សណ្តែកបាយ | ៣០គុម | ជាតិស្រេច |

| | | | |
|---|---|---|---|
| | ល្ហុង | ៩រង | -ខ្វះប្រភពទឹក |
| | សាគូសរ | ៣រង | -ទឹកលិច ខែ០៨-១០ ឆ្នាំ២០១០ |
| | ដំឡូងឈាមមាន់ | ៤គុម | -សត្វល្អិតបំផ្លាញ(មមែកត្នោត មមាចខៀវ |
| | ស្លឹកខ្ទឹម | ១០រង | ដង្កូវស៊ីរូងដើម អណ្ដើងមាស |
| | ល្ពៅ | ២ទ្រើង | ស្រង់ដញ្ជក់ទឹកដោះ ចង្រិត) |
| | ល្មៀត | ៦គុម | -អាសន្នរោគមាន់ ដង្កោកាច់ ពកមាត់ ពកក្អែក |
| | រំដេង | ១គុម | មូលករ |
| | ពពាយ | ២ទ្រើង | -ជ្រូកឈឺ កូនជ្រូករាគ ពណ៌សរ មូលមាត់ |
| | ចិញ្ចឹមមាន់ | ៣៤ក្បាល | ទន់ដៃទន់ជើង អុតក្តាម ។ |
| | ចិញ្ចឹមជ្រូក | ៥ក្បាល | -ប្រើជីកំប៉ុស្តិ៍ទឹកមានស្រមោចឡើងដើមដំណាំ |
| | ចិញ្ចឹមជន្លេន | ៤កន្លែង | **+ ដំណោះស្រាយ** |
| | ចិញ្ចឹមទា | ៨ក្បាល | - |
| | ធ្វើជីកំប៉ុស្តិ៍ទឹក | ៦០លីត្រ | មាន់ឈឺយកវ៉ាក់សាំងលាយទឹកឱ្យផឹកហៅពេទ្យ |
| | ធ្វើជីកំប៉ុស្តិ៍គោក | ១៦៦៦០គីឡូ | មកព្យាបាល |
| | ថ្នាំបណ្តេញសត្វល្អិត | ២ធុង | **+ បទពិសោធន៍ និងមេរៀនដែលបានរៀន** |
| | ចាក់វ៉ាក់សាំងមាន់ | ២ដប | -ការកែប្រែគុណភាពដី ដីរឹង ដីអិល |
| | ជីអ៊ុអ៊ឹម | ១ធុង | មកជាដីជ្រាយវិញ |
| | ធ្វើស្រែប្រាំង | ១២៦០គីឡូ | -ប្រើពេលវេលាតិច |
| | ជីកស្រះ | ១=១២គុណ៥ | (ស្រែធ្លាប់ស្ទូង៣នាក់) ក្រោយពីការដាក់ |
| | | | ជីមកស្ទូងតែ២នាក់ក្នុង១ថ្ងៃដោយមិនខំ |
| | | | -ការចាប់អារម្មណ៍ពីអ្នកភូមិ |
| | | | (សួរនាំការប្រើប្រាស់ជី ឃើញពីទិន្នផល ហើយយកទៅអនុវត្តន៍តាម ) ។<br>-ចេះកែច្នៃធនធានដែលមានស្រាប់នៅក្នុងភូមិ ។<br>-<br>យល់ពីសារៈសំខាន់ពីធនធានដែលមានយកទៅប្រើ-កែប្រែផ្នត់គំនិត-ចេះប្រើពេលវេលា ។<br>-ផ្តល់សុខភាពល្អ ស្រែ ស្រូវ បន្លែ សត្វ ☐ |

| | | | |
|---|---|---|---|
| | | | ប្រជាជនចូលចិត្ត ទិញបន្លែដាំ ជាងបន្លែទីផ្សារ ។<br>-ប្រើប្រាស់កំលាំងពលកម្មអស់លទ្ធភាព<br>សមាជិកគ្រួសារជួយ<br>បានគ្រប់គ្នា ។ |

# របាយការណ៍សកម្មភាពរយៈពេល៦ ខែ

## អង្គការ **HRND** ខេត្ត សៀមរៀប

| ល-រ | សកម្មភាព | លទ្ធផល | បញ្ហា | ដំណោះស្រាយ |
|---|---|---|---|---|
| ១ | ប្រជុំក្រុមកសិករ ពង្រីក | ៤ លើក៦ភូមិអ្នកចូលរួម ១៤០នាក់ ស្រី ១២៣ | | |
| ២ | បើកវគ្គបណ្តុះបណ្តាលគ្រូ និង សិស្ស | ៤ ភូមិ ៤សាលាអ្នកចូលរួម ២១០ នាក់ ស្រី ១០៨ នាក់ | | |
| ៣ | បង្កើតក្រុមសន្សំប្រាក់ | អ្នកចូលរួម ២៦ នាក់ ស្រី ២០នាក់ | ក្រុមមិនមានគោលនយោបាយ<br>ច្បាស់លាស់ក្នុងការខ្ចីប្រាក់ | |
| ៤ | ប្រជុំក្រុមធនាគារស្រូវពីរកន្លែង | ១២លើអ្នកចូលរួម២៦៤នាក់ ស្រី២១៤ នាក់ ស្រូវសរុប ៦៣៦០ គីឡូ | | កំពុងរៀបចំឯកសារលក្ខន្តិកៈ នៅក្នុងក្រុម |
| ៥ | ប្រជុំក្រុមកសិករគំរូ បើកវគ្គបណ្តុះបណ្តាលធ្វើជី និង ថ្នាំសំលាប់សត្វល្អិត | -បានផ្លាស់ប្តូរបទពិសោធន៍ គ្នាទៅវិញទៅមក<br>-៧<br>លើកអ្នកចូលរួម៨២នាក់ ស្រី ២៦ នាក់ | ការធ្វើជីនិងថ្នាំសំលាប់សត្វល្អិតយកទៅប្រើគ្មានប្រសិទ្ធភាព | |
| ៦ | ប្រជុំពង្រឹងសមត្ថភាព ក្រុមដាំបន្លែ | ៣ លើកអ្នកចូលរួម ៤៨ នាក់<br>ស្រី ៤៥ នាក់ | | |
| ៧ | ចូលរួមផ្សព្វផ្សាយធ្វើវត្ថុកែច្នៃពីធម្មជាតិ | អ្នកចូលរួម ១៨ នាក់ ស្រី ១៦ នាក់ | | |

| | | | | |
|---|---|---|---|---|
| ៨ | ចុះតាមដានសកម្មភាព | ១០០ គ្រួសារ | | |
| ៩ | ចូលរួមប្រជុំបង្កើតគណៈកម្មការទីផ្សារ | អ្នកចូលរួម១៦នាក់ស្រី១០នាក់ ៨ ភូមិ | | |

**–** យោបល់ចូលរួម លោក វិឆ័យ នាយកអង្គការ **MPC** មានប្រសាសន៍ថាបើសិនជាយើងគិតចំពោះ ក្រុមកសិករគំរូ ៤ គ្រួសារ សកម្មភាពនេះវាច្រើនណាស់សំរាប់ពួកគាត់ យើងត្រូវគិតឡើងវិញពីសកមភាពរបស់ពួកគាត់។ លោកគឹម ភី មកពីខេត្តកំពត បាន

សួរថា ហេតុអ្វីបានជាខាងអង្គការ **HRND** មិនមានថវិកាសំរាប់គាំទ្រការប្រជុំរបស់ក្រុមកសិករ**. . . ?**
ចំលើយ **:** អង្គការ **HRND** មិនបានដាក់ខ្ទង់ថវិការសំរាប់គាំទ្រលើការប្រជុំរបស់ក្រុមកសិករនេះទេ នៅក្នុងឆ្នាំ ២០១០នេះ ។

**អង្គការHRDCSO ស្រុករៀង** <u>របាយការណ៍ប្រចាំឆ្នាំ២០១០</u>

លទ្ធផលនៃការអនុវត្តផ្នែកកសិកម្មរបស់កសិករគំរូទាំង៤

| ល–រ | សកម្មភាព | កាលបរិច្ឆេទ | លទ្ធផលទទួលបាន | បញ្ហា | ដំណោះស្រាយ |
|---|---|---|---|---|---|
| ១ | ដាំស្ពៃ ត្រកួន ត្រសក់ សណ្តែកគួរ ផ្ទី ប៉េងបោះ សាលាដ | ពីខែ ០១ ដល់ខែ ១១ ឆ្នាំ ២០១០ | ដាំបានចំនួន២៦០រង ហើយលក់បានប្រាក់ចំណូល ៤៥២២៥០០រៀលនិងរក្សាទុកគ្រាប់ពូជសំរាប់ដាំបន្តរ | –ដីជាំទឹកនៅរដូវវ៉ាស្សា<br>–ខ្វះទឹកបន្ថែមនៅរដូវរប្រាំង<br>–ប៉េងប៉ោះ ស្ពៃរលួយ | –រដូវវស្សាដាំបន្ថែមតាមស្ទួន ក្បាលស្រែ<br>–ដកដើមណារលួយចេញ |
| ២ | ចិញ្ចឹមមាន់ ទា | ពីខែ ០១ ដល់ខែ ១១ ឆ្នាំ ២០១០ | ចិញ្ចឹមមាន់និងទាបានចំនួន ៣២៩ក្បាលលក់អស់៩៩ក្បាលស្មើ១២១ គីឡូបានប្រាក់ចំណូល១៤៥២០០០រៀល | កូនមានតូចៗមានជំងឺអុត និង ស្លាប់ | –បុកស្លឹកក្រេម ក្រមលាយជាមួយកំបោរលាប |
| ៣ | ចិញ្ចឹមត្រីអណ្តែងត្រីស្រែ? | ពីខែ ០៤ ដល់ខែ ១១ ឆ្នាំ ២០១០ | ចិញ្ចឹមត្រីអណ្តែងចំនួន៣ស្រះដាក់កូនត្រីចំនួន៣២០០ក្បាលចាប់លក់អស់២០គីឡូបានប្រាក់ចំណូល២០០០០០រៀល | ត្រីធំមិនស្មើគ្នា | |

| | | | | | |
|---|---|---|---|---|---|
| ៤ | ចិញ្ចឹមជ្រូក | ពីខែ ០១ ដល់ខែ ១១ ឆ្នាំ ២០១០ | ចិញ្ចឹមជ្រូកបាន១៣ក្បាលលក់អស់៥ក្បាលហើយនិងលក់កូន៦ក្បាលបានប្រាក់ចំណូល ២៣៩១០០០រៀល | | |
| ៥ | ដាំស្វាយ ក្រូច ដូង ខ្នុរ ល្ហុង ចេក | ពីខែ ០៦ ដល់ខែ ១១ ឆ្នាំ ២០១០ | ដាំស្វាយ៣០ដើម ក្រូច១៥ដើម ដូង២០ដើម ល្ហុង១៥ដើម ចេក១០ដើម ខ្នុរ៤ដើម | | |
| ៦ | ដាំសណ្តែកសៀង | ពីខែ ០៧ដល់ខែ ១១ ឆ្នាំ ២០១០ | បានដាំសណ្តែកសៀងនៅលើដីចំការចំនួន៣ហិចតាទទួលផលបាន៥០០០គីឡូ | | |
| ៧ | បណ្តុះផ្សិតចំបើង | ពីខែ ០៤ ដល់ខែ ១១ ឆ្នាំ ២០១០ | បានបណ្តុះផ្សិតចំបើង២រង ១x ៥ម លក់បានប្រាក់ចំណូល ៣០០០០០រៀល | | |
| ៨ | ធ្វើស្រែ | ពីខែ ០៧ ដល់ខែ ១១ ឆ្នាំ ២០១០ | ធ្វើស្រែបាន៨.៥០ ហិចតា និងស្ទូងស្រូវដើមបាន៥ ស្រែ | | |
| ៩ | ដាំល្ពៅ ត្រលាច ននោង ឃ្លោក ម្រះ ស្លឹកគ្រៃ | ពីខែ ០១ ដល់ខែ ១១ ឆ្នាំ ២០១០ | បានចំនួន១០ទ្រើងលក់បានប្រាក់ចំណូល២០០០០០រៀល ហើយនិងរក្សាទុកគ្រាប់ពូជសំរាប់ដាំបន្ថែមទៀត | ព្រះវិហារ | |
| ១០ | ការពង្រីកក្រុមកសិករ | ពីខែ ០១ ដល់ខែ ១១ ឆ្នាំ ២០១០ | បានចំនួន១៦៥នាក់ស្មើរនិង៣៣ក្រុមនៅក្នុងចំនួន៧ភូមិ ហើយពួកគាត់បានដាំដុះបន្លែដូចជា: ស្ពៃ ត្រកួន ត្រសក់ សណ្តែក ផ្ទី ននោង ខាត់ណា សាលាដ | | |

-**បន្តមកទៀត បងស្រី ស៊ិន ស៊ីណន** បានបង្ហាញពីរបាយការណ៍២០១០របស់កសិករគំរូ៤នាក់ របស់អង្គការ **HOM** ខេត្តកំពង់ធំ

I ពង្រឹកកសិករ

-ជំហានទី១ ១នាក់ x ៥នាក់ក្នុង១៦ភូមិ=៨០ នាក់

-ជំហានទី២ ៨០នាក់ x ៤នាក់ក្នុង១៦ភូមិ=៣២០ នាក់

-ដាំខ្ទឹមដើម៣១ រង ១ម x ៨ម (លក់បាន២៨រាន=១ម x ៤ម ៣៤០០០០រៀល)

-ដាំត្រកួន ៣១ រង ១ម x ២២ម លក់បាន១២៩៤០០ រៀល

-ម្រះ ៧៧ កុម្ភ = ៣១ ទ្រើង លក់បាន ៣៩០០០០ រៀល

– ក្រុមកសិករគំរូរបស់អង្គការ HOM បានទៅទស្សនៈកិច្ចនៅហាណូយហើយក្រោយពីត្រឡប់មកវិញ គាត់បានអនុវត្តន៍បានពីរ

ករណីទៀតហើយទៅលើការធ្វើជីកំប៉ុស្តិ៍ដោយប្រើខ្ទង ។

បញ្ហាដែលជួបប្រទះ: ដំណាំជួបគ្រោះមហន្តរាយ ខ្វះធនធាន

– ដំណោះស្រាយ: ជីកស្រះ លើករាន ប្រើដបទឹកសុទ្ធ

–សំនួរ: លោក វិឆ័យ បានសួរថា តើធ្វើធានាគារស្រូវមាននិរន្តភាពបែបណាសំរាប់ទៅថ្ងៃខាងមុខ?

**ចំលើយ:** ដោយសារធានាគារស្រូវរបស់HOM មានតិចវាស្រួលគ្រប់គ្រង

បើសិនជាមានច្រើនក៏ពិបាកគ្រប់គ្រងណាស់មិនដឹងថា

យ៉ាងណាសំរាប់ថ្ងៃខាងមុខ ។

លោក សាមេធ មកពីខេត្ត សៀមរាប បានចូលរួមយោបល់ថាក្រុមសន្សំនេះ

បើនៅតាមឯកសារនៅប្រទេសឥណ្ឌា គេនិយាយថា ក្រុមសន្សំបើសិនជាក្រុមនោះមិនមានចំនូល

ពួកគាត់មិនអាចសន្សំបានទេ ជាទូរទៅមុននឹងសន្សំប្រាក់ គឺក្រុមនោះត្រូវ

តែរកបានចំណូលអ្វីមួយទើបពួកគាត់អាចមានលទ្ធភាពសន្សំបាន បើពួកគាត់រកចំណូលមិនបាន ពួកគាត់សន្សំមិនបាន ថ្ងៃណាមួយ

ពួកគាត់ នឹង ចាកចេញមិនខាន។ កញ្ញា បុគ្គលិកអង្គការ HOM បានចូលរួមយោបល់ថា :

ក្រុមសន្សំនេះគឺមិនមែនការសន្សំនៅក្នុង

សហគមន៍ទាំងមូលទេ គឺការសន្សំនេះពួកគាត់សន្សំដោយស្មគ្រ័ចិត្តសំរាប់ការជួយគ្នាទៅវិញទៅមក

ដោយមិនគិតការប្រាក់ហើយ

សន្សំតែប៉ុន្មាននាក់ក្រុមគ្នាគាត់តែប៉ុណ្ណោះ។

**–បទបង្ហាញបន្ត គឺក្រុមកសិករគំរូមកពីអង្គការ ADIFE** ខេត្តស្វាយរៀង

មានក្រុមកសិករ៤នាក់តែការបង្ហាញនេះបានក្រុមកសិករ

តែមួយគ្រួសារប៉ុណ្ណោះ ។

I កសិករគំរូឈ្មោះមៅ សារិន

- ដាំសណ្តែកគួរ
- ត្រសក់
- ដំឡូងមី
- ចិញ្ចឹមមាន់ ជ្រូក
- ធ្វើស្រែប្រាំង
- ដីកំប៉ុស៍

សរុប: ១៣៤៥000 រៀល ចំណាយ: ៣៤0000 រៀល ចំណូល ១00៥000 រៀល

II . កសិករគំរូឈ្មោះប៉ែន ហុក

- ត្រសក់

២. ស្លឹកគ្រៃ

៣. រមៀត

៤. ននោង

៥. ដំឡូងមី

៦. ត្រឡាចសឹកគ្រៃ

សរុប: ៣៤១000 រៀល ចំណាយ: ១៥0000 រៀល ចំណូល: ១៩១000 រៀល

ជាបញ្ហាសំរាប់ក្រុមកសិករគំរូការដាំត្រសក់រលួយគល់នឹងស្រាំងទិច ។

សំនួរ : លោក ចេង វីរៈ បានសួរថា តើមុននឹងយើងបានទិន្នន័យទាំងអស់នេះមកកាលដែលគាត់មិនទាន់ដាំ និង មិនទាន់ចូល

ក្នុងកសិករគំរូ ពួកគាត់មានដាំអ្វីខ្លះ? បើយើងមិនស្រង់ទិន្នន័យពីមុនមកយើងបានអ្វីយកមកធ្វើការវាស់វែងពីព្រោះថាដំណាំ ទាំងនេះអាចមានពីមុនមកហើយ អញ្ចឹងសូមយើងគិតឡើងវិញទាំងអស់គ្នា ។

ពីប្រព័ន្ធធារាសាស្ត្រ

- ពីបច្ចេកទេសដាំផ្លែក្រូច
- ពីចច្ចេកទេសដាំដំណាំស្រូវ និង ការបង្កាត់ពូជស្រូវ
- ពីគំរោងកាត់ដេរសំលៀកបំពាក់ប្រពៃណីជនជាតិ ភូមិឡា
- ពីបច្ចេកទេសចិញ្ចឹមកាំប្រមា នៅក្រុងគីសួន

- ពីការចិញ្ចឹមឃ្មុំ នៅភូមិ មី
- ពីបច្ចេកទេសធ្វើជីកំប៉ុស៍
- ការធ្វើវ៉ារីអគ្គីសនី នៅហាណូយ
- ការទៅទស្សនៈកិច្ចសិក្សាបន្លែសីរីរាង្គ

ចំណុចដែលបង្ហាញបន្ថែមគឺ ការដាំដំណាំទាំងអស់ គឺគេប្រើជីគីមី អត់ប្រើតែការដាំបន្លែសេរីរាង្គតែប៉ុនណ្ណោះ ព្រោះអីរដ្ឋាភិបាលបាននិយាយថា ស៊ូអោយកសិករប្រើជីគីមីតែមិនអោយកសិករគេដាច់ពោះស្លាប់នោះទេ នេះជាយុទ្ធសាស្ត្រសំរាប់ប្រទេសគេ ។

–បន្ទាប់ពីការចែករំលែកបទពិសោធន៍ពីការទៅទស្សនៈកិច្ចសិក្សានៅហាណូយប្រទេសវៀតណាមរួចមក...... ។

លោក សុផល

ប្រធានបណ្តាសហគមន៍អធិបតេយ្យភាពស្បៀងនៅកម្ពុជាបានបង្ហាញពីរបាយការណ៍និងលទ្ធផលរបស់ក្រុមស្នូលបណ្តាញអធិតេយ្យភាពស្បៀងនៅកម្ពុជាដែលមាន ខ្លឹមសារភ្ជាប់នូវខាងក្រោម។

សំរាប់បញ្ហាជួបប្រទះរបស់ក្រុមស្នូលមាន៣ សំខាន់ៗ

–ការសំរេចចិត្តរបស់ប្រធានបណ្តាញ

–ធ្វើការត្រូវបានផ្លាស់ប្តូរមិនបានដឹងមុន

–សុំអោយមានការប្រជុំបណ្តាញដើម្បីរៀបចំគោលការណ៍របស់បណ្តាញ

បន្តមកទៀត លោក ចេង វិរៈ បានដាក់សំនួរពិភាក្សាដល់សមាជិកបណ្តាញដែលផ្តោតសំខាន់ទៅលើការចងក្រងសហគមន៍

សំនួរ

សំនួរពិភាក្សាត្រូវបានចែកចេញជា៣ក្រុម

ក្រុមទី១ ដែលបានទៅទស្សនៈកិច្ចនៅប្រទេសវៀតណាម ៥ នាក់ មាន១សំនួរ

យកបទពិសោធន៍ដែលបានរៀនសូត្រ រៀបចំផែនការអនុវត្តសំរាប់អង្គការរបស់ខ្លួន ក្នុងឆ្នាំ២០១១

ក្រុម ទី២CO ៦ នាក់ មានពីរសំនួរ

- តើការគាំទ្រផ្នែក CO ពីអង្គការអាក់សិនអេតកន្លងមក មានសារៈប្រយោជន៍អ្វីខ្លះ? ដល់អង្គការអ្នក និងសហគមន៍គោលដៅរបស់អង្គការ ។

- តើអង្គការមានសមត្ថភាពគ្រប់គ្រាន់ក្នុងក្នុងការប្រើប្រាស់ ដំណើរការ CO ហើយឬនៅ ? បើទេ តើត្រូវការអ្វីខ្លះ ដែលអ្នកគិតថា ក្រុម CO អាក់សិនអេត ត្រូវបំពេញបន្ថែមដល់បុគ្គលិកអង្គការ ? ក្រុមសកម្មក្នុងសហគមន៍ ។

ក្រុមទី៣ ក្រុម បណ្តាញ សំនួរ មាន៤សំនួរ

- តើ **CNFSC** បណ្តាញសហគមន៍ដើម្បីអធិបតេយ្យ ស្បៀង នៅកម្ពុជា សំរេចបានសទ្ធិផលសំខាន់ៗ អ្វីខ្លះ ?
- តើ **CNFSC** នៅមានចំនុចខ្វះខាតអ្វីខ្លះ ឧបសគ្គអ្វីខ្លះ.
- សូមផ្តល់យោបល់ ដើម្បីឱ្យប្រសើរឡើងនូវ **CNFSC** សំរេចបានតាម គោលដៅ គ្រោងទុក និងការកែលំអ រសំរាប់ឆ្នាំ ២០១១
- តើសមាជិកបណ្តាញត្រូវការជំនាញ/ចំណេះដឹង/បទពិសោធន៍អ្វីខ្លះបន្ថែមទៀត នៅឆ្នាំ ២០១១

ក្រុម **CO** ពិភាក្សា១សំនួរគឺសារៈប្រយោជន៍ **CO** ដល់អង្គការដៃគូសម្ពភាពអ្វីខ្លះដែលក្រុម **CO** ចង់បានបន្ថែម ក្រុមទៅទស្សនៈកិច្ចនៅប្រទេសវៀតណាម

–យកបទពិសោធន៍ដែលបានរៀនសូត្ររៀបចំអនុវត្តដល់អង្គការរបស់ខ្លួន

**ក្រុមបណ្តាញមាន៤សំនួរ**

–សមិទ្ធផលសំខាន់ៗអ្វីខ្លះដែលសំរេចបាន

–តើ **CNFSC** នៅមានចំណុចខ្វះខាត ឧបសគ្គអ្វីខ្លះ?

–សូមផ្តល់យោបល់ដើម្បី ធ្វើអោយប្រសើរនូវ **CNFSC**

- សមាជិកបណ្តាញត្រូវការជំនាញ ចំណេះដឹង បទពិសោធន៍អ្វីខ្លះ? ។

**ចំលើយ ពិភាក្សា:**

**សំរាប់ចំលើយក្រុមទី១ :**

- រៀបំពិនិត្យ មើល លើរចនាសម្ពន្ធ័ គោលការណ៍របស់បណ្តាញ
- ផ្សព្វផ្សាយបច្ចេកទេសធ្វើសេរីរាង្គ និងប្រពន្ធ័កសិកម្មចំរុះ
- សាល្បងបច្ចេកទេស ពិសោធន៍ជីសេរីរាង្គ ១កន្លែង
- រៀបចំប្រពន្ធ័កសិកម្មចំរុះខ្នាតតូច ១កន្លែង

**សំរាប់ចំលើយ ក្រុមទី២**

- សារៈប្រយោជន៍ CO ដល់អង្គការ ?

–ចេះវិភាគបញ្ហាបានស៊ីជំរៅ និងរៀបចំផែនការ

–របៀបដោះស្រាយបញ្ហា និង អនុវត្តន៍សកម្មភាពចំគោលដៅ

–មានជំនាញសំរបសំរួល

–មានការទំនាក់ទំនងល្អ ជាមួយអាជ្ញាធរ និងស្ថាប័នពាក់ពន្ធ័

**+ សារៈប្រយោជន៍** CO **ដល់សហគមន៍**

–ធ្វើឱ្យប្រជាពលរដ្ឋយល់ពីសិទ្ធី និង មានសិទ្ធិគ្រប់គ្រងលើធនធានរបស់សហគមន៍ និងមានធនធានមនុស្ស

-ចេះរកព័ត៌មាន និង វិភាកព័ត៌មាន

-កំណត់បញ្ហា និងធ្វើផែនការរួមគ្នា មានគោលដៅច្បាស់លាស់

-មានជំនាញទំនាក់ទំនង អាជ្ញាធរ និងស្ថាប័នពាក់ពន្ធ័

-និងមានសិទ្ធិដោះស្រាយបញ្ហា និង ជួយជំរុញក្នុងការអនុវត្តន៍សង្គម ។

២- ពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងដំនើរការ CO ទេ

តំរូវការត្រូវបំពេញបន្ថែម

-បន្តពង្រឹង ការឆ្លុះបញ្ចាំង ផ្នែក CO

-អាក់សិនអេតបន្តបណ្តុះបណ្តាញផ្នែក CO ដល់បុគ្គកល និង ក្រុមសកម្មភាពក្នុងសហគមន៍មូលដ្ឋាន

-ពង្រឹងបន្ថែម គ្រូបង្គោលCO

-បណ្តុះបណ្តាលច្បាប់ដល់ក្រុម CO ច្បាប់ភូមិបា/ ព្រហ្មទណ្ឌ/ ដលផល

-ផ្តល់ឯកសារ ផ្នែកគោលនយោបាយក្នុងការអភិវឌ្ឍន៍ប្រទេស ។

**+ សំរាប់ចំលើយក្រុមទី៣**

**១ / CNFSC សមិទ្ធផលសំខាន់ៗដែលសំរេចបាន រួមមាន**

- ទស្សនៈកិច្ចសិក្សា ក្នុង និងក្រៅប្រទេស

- ភ្ជាប់បណ្តាញ តាមអង្គការដៃគូ និង អន្តរជាតិ

- ចងក្រងបណ្តាញក្រុមកសិករគំរូ ក្រុម១ និង ក្រុម២

- ពង្រឹងសមត្ថភាពដល់ក្រុមស្នូល និងសមាជិកបណ្តាញ

**២/ ចំណុចខ្វះខាត**

- ការទំនាក់ទំនងរបស់ក្រុមស្នូល និងសមាជិកបណ្តាញ
- ការសំរេចចិត្ត របស់ប្រធាន
- ការផ្លាស់ប្តូរផែនការ មិនតាមផែនការ
- ការទទួលខុសត្រូវមិនច្បាស់លាស់

ចំណេះដឹងរបស់ក្រុមស្នូលនៅមានកំរិត ភាសា,កុំព្យូទ័រ, អ៊ីម៉ែល ការដឹកនាំ .ការទំនាក់ទំនង .... ។ល។

**ឧបសគ្គ :**

**-មិនមានរចនាសម្ពន្ធ័ គោលការណ៏ លក្ខន្តិកៈ ច្បាស់លាស់**

-សមាជិកបណ្តាញមួយចំនួន មិនទាន់ស្គាល់ពីគោលបំណង និងសកម្មភាពរបស់បណ្តាញ

-ការផ្តល់ដំណឹងដល់សមាជិកពុំទាន់ពេលវេលា និងមិនច្បាស់លាស់

- ការរៀបចំធ្វើផែនការ មិនមានការចូលរួមពីសមាជិកបណ្តាញ

**៣–យោបល់CNFSC សំរេចគោលដៅគ្រោងទុក និងធ្វើការកែលំអរ សំរាប់ឆាំ ២០១១**

–ស្នើរសុំប្រជុំក្រុមស្នូលរយៈ២ថ្ងៃ ដើម្បីពិនិត្យ មើលគោលការណ៍គ្រប់គ្រងរបស់បណ្តាញ និង ហិរញ្ញវត្ថុ

–បណ្តាញត្រូវចូលរួម ធ្វើផែនការដោយផ្ទាល់

–ប្រជុំក្រុមស្នូលឱ្យបានទៀងទាត់ រាល់ត្រីមាស

–ប្រជុំក្រុមស្នូល និងសមាជិកបណ្តាញ ឆ្នាំ២ ដង

–សមាជិកក្រុមស្នូល និងសមាជិកបណ្តាញកុំមានការផ្លាស់ប្តូរនៅតាមអង្គការដៃគូ

–មន្ត្រីអាក់សិនអេតទទួលបន្ទុកតាមអង្គការដៃគូ ត្រូវផ្តល់ពត៌មានឱ្យបានរយៈពេល ១០ថ្ងៃមុន

–ការផ្តល់ពត៌មានទៅដល់សមាជិកបណ្តាញតាមទូរសព្ទ

**៤– ការពង្រឹងសមត្ថភាពក្រុមបណ្តាញ**

– បណ្តុះបណ្តាញច្បាប់ដលផល ដីធ្លី ព្រហ្មទណ្ឌ ព្រៃឈើ

– ជំនាញក្នុងការទំនាក់ទំនង

– ជំនាញក្នុងការរៀបំកម្មវិធី

– ជំនាញក្នុងការគ្រប់គ្រងគំរោង

– បច្ចេកទេសកសិកម្ម

– ចងក្រងសហគមន៍

នៅពេលក្រុមទាំងបី បានធ្វើការបង្ហាញរួចមក លោក ស៊ីវត្ថា បានលើកឡើងនៅចំនុចមួយ របស់ក្រុមបណ្តាញ គឺចំនុចលើការរៀបចំ រចនាសម្ពន្ធ័ របស់ក្រុមស្នូលបណ្តាញអធិបតេយ្យភាព អាក់សិនអេត កំពង់តែគិតទៅដល់បញ្ហារចនាសម្ពន្ធ័របស់ក្រុម ស្នូលនេះដែរ ពីព្រោះកន្លងមកយើងមើលឃើញថា ក្រុមស្នូលអធិបតេយ្យ ស្បៀងមានភាពរញ៉េរញ៉ៃណាស់ មិនមានអ្នកទទួលខុស ត្រូវពិតប្រាកដ ។ ភ្ជាប់ទៅនឹង ចំនុចនេះ កញ្ញា ផុន រដ្ឋាបានលើកឡើងថាៈ ក្រុមបណ្តាញត្រូវនិយាយពីរឿងរចនាសម្ពន្ធ័ ឱ្យបាន ច្បាស់លាស់ កន្លងមកខ្ញុំមិនមិនមែនជាសមាជិកក្រុមស្នូលបណ្តាញអធិបតេយ្យភាពស្បៀងទេ គឺគ្រាន់តែជាជំនួយការ សំរាប់ជួយតែប៉ុណ្ណោះ ថ្ងៃណាមួយខ្ញុំនឹងឈប់នៅអាក់សិនអេតហើយ ។ អញ្ចឹងហើយសូមឱ្យក្រុមស្នូលគិតពីរឿងនេះឡើងវិញ។ បន្ទាប់ពីមានការចូលរួមយោបល់ និង ការផ្តល់ជាអនុសាសន៍ពីតំណាងអង្គការអាក់សិនអេតចប់រួចរាល់ លោក ស៊ីវត្ថាបានបង្ហាញពី វិធីសាស្រ្តមួយចំនួន ដែលធ្វើយ៉ាងណាឱ្យមានការចូលរួម ពីប្រជាជន ក្រុមគោលដៅ ក្នុងដំណើរការអភិវឌ្ឍន៍ របស់ អង្គការដៃគូ

បន្តមកទៀត លោក ចេង វិរៈ បុគ្គលិកអាក់សិនអេត បានចូលរួមបង្ហាញពី របៀបនៃការថតរូប ធ្វើយ៉ាងណាឱ្យមានគុណភាពល្អ ហើយយកទៅប្រើប្រាស់ ដែលធ្វើឱ្យអ្នកមើលចាប់អារម្មណ៍**វិធីថតរូបឱ្យបានល្អឥតខ្ចោះ ព្យាយាមហើយព្យាយាមទៀត)**

- **រៀបចំផែនការ**

មុនពេលចេញទៅថតរូប អ្នកគួរតែកំណត់គោលបំណងឱ្យបានច្បាស់លាស់។ តើអ្នកត្រូវការរូបប្រភេទណា? តើអ្វីជា ប្រធានបទនៃរូបភាព? តើសារអ្វី ដែលអ្នកព្យាយាមបញ្ជូនតាមរូបភាពអ្នក?
តើអ្នកណាជាទស្សនិកជនរបស់អ្នក?
ទាំងនេះធ្វើឱ្យអ្នកមានគំនិត ថាតើរូបភាពបែបណាដែលត្រូវតាមគោលបំណងអ្នក។

- **ថតឱ្យបានច្រើនប្រភេទរូប**

ព្យាយាមថតប្រភេទផ្សេងៗ ដូចជាថត ឆ្ងាយ មធ្យម ទូលាយ បញ្ឈរ ជិត ជិតខ្លាំង។ រូបថតរឿងនិទាន ដែលល្អ គួរបញ្ចូលគ្រប់ប្រភេទទាំងនេះ។ ហើយព្យាយាមថតទាំងផ្ដេក និង បញ្ឈរ។

- **ទីតាំងថតផ្សេងៗ**

កុំឈរថតតែមួយកន្លែង ប៉ុន្តែព្យាយាមដើរជុំវិញវត្ថុត្រូវថត។ គិតពីលទ្ធភាពជ្រុង និងចំងាយផ្សេងៗ ដែលអាចថតបានរូបល្អ។ ព្យាយាមថតពីក្រោម ឬ ឈរលើកៅអីដើម្បីថតរូបពីលើ។

- **ផ្ដោតលើប្រធានបទមួយ**

អ្នកថតពីអ្វីក៏ដោយ ត្រូវឱ្យវាឆ្លើយទៅនឹងប្រធានបទមួយ ដែលអ្នកបានគ្រោង។ ពិនិត្យ ឡើងវិញ និង ពង្រឹងសាររបស់អ្នក ទៅលើប្រធានបទមួយ តាមរយះរូបថត

- **ត្រូវមានភាពច្នៃប្រឌិត**

ចំពោះការថតជាក្រុម កុំឱ្យមនុស្សឈរជាជួរ។ ត្រូវមានការច្នៃប្រឌិតឱ្យបានច្រើន។ ឱ្យពួកគាត់នៅ ចំងាយផ្សេងៗគ្នាពីម៉ាស៊ីនថត ឱ្យឃើញជាលក្ខណៈធម្មជាតិ តែត្រូវគ្រប់គ្រងវត្ថុបំណងអ្នក។ គិតពីរូបត្រូវថត និងរូបខាងក្រោយដែលបំពេញន័យឱ្យរូបត្រូវថត។

- **ធ្វើខ្លួនជា ជាងថតរូប**

ចងចាំថា អ្នកជា ជាងថត។ ដូចនេះអ្នកត្រូវតែអត់ធ្មត់ កំប្លុកកំប្លែង និង ធ្វើភ្លីភ្លើ។ វោហាសព្ទ និង កាយវិការកំប្លុកកំប្លែង តាមបែបវិជ្ជមាន គ្រាន់តែ ការកំប្លែង ដើម្បីទទួលបានសំណើច និង

ស្នាមញញឹមពីកុមារប៉ុណ្ណោះ។ កុំមានការខ្មាស់អៀនក្នុងការធ្វើវា។ អ្នកត្រូវតែមានការអត់ធ្មត់ ដើម្បីចំណាយពេលជាមួយមនុស្ស។

- **ព្យាយាមបែបបទថ្មីៗ**

ការថតរូបជាសិល្បៈនៃការបង្ហាញរូបភាព។ វាពុំមានដែនកំណត់ទេ ដូចនេះព្យាយាមរបៀបថ្មីៗ។

# ការវាយតំលៃវគ្គ

- **តើមានអ្វីខ្លះដែលអ្នកបានរៀនសូត្រពីសិក្ខាសាលានេះ?**

- ចេះពីរបៀបធ្វើខ្លួនជាអ្នកសំរបសំរួល និង ពិភាក្សាក្រុម
- ទទួលបានបទពិសោធន៍ ពីការដាំដុះ បន្លែ បង្ការ ចិញ្ចឹមសត្វមាន់ ត្រី.ធ្វើជីកំប៉ុស្តិ៍ ។
- យល់កាន់ច្បាស់ពីបទពិសោធន៍ផ្សេងៗតាមបណ្តាអង្គការនានា
- បានរៀនសូត្រពីការបង្ហាញតាមអង្គការដៃគូរ និង រៀនសូត្រអ្នកសំរបសំរួល
- ឈ្លដឹងពីក្រុមការងាររបស់ ក្រុមស្នូលបណ្តាញបានច្បាស់លាស់ និង ចំណេះដឹងថ្មីៗក្នុងការថតរូប
- យល់ដឹងពីគោលបំណងរបស់ក្រុមបណ្តាញCNFSC
- ដឹងពីបញ្ហាដែលជួបប្រទះតាមបណ្តាអង្គការ
- ត្រូវរៀបចំរចនាសម្ពន្ធ័ក្រុមបណ្តាញឱ្យបានច្បាស់លាស់
- បានរៀនសូត្រពីសិក្ខាសាលានេះ បានពង្រឹងចំណេះដឹងបានមួយកំរិត
- បានរៀនបទពិសោធន៍ ពីប្រទេសវៀតណាម

- **តើមានអ្វីខ្លះ ដែលគួរធ្វើឱ្យប្រសើរឡើង នៅពេលក្រោយ?**

- ត្រូវរៀបចំឯកសារដល់អ្នកពាក់ពន្ធ័ចែកជូនដល់អ្នកចូលរួម
- ត្រូវជំរាបអ្នកចូលរួមឱ្យបានមុនរយៈ ៥-៧ថ្ងៃ
- ត្រូវគោរពទៅតាមពេលដែលបានកំណត់
- យកចំណេះដឹង និង បទពិសោធន៍ ទៅចែករំលែកដល់សហគមន៍ គោលដៅ ឱ្យអនុវត្តន៍បន្ត
- លិខិតអញ្ជើញសូមផ្តល់ឱ្យបានមុនយ៉ាងហោចណាស់១០ថ្ងៃ
- មុននឹងបើកវគ្គបណ្តុះបណ្តាល ឬ សិក្ខាសាលា ប្រជុំផ្សេងៗត្រូវរៀបចំចាត់ចែង ការទទួលខុសត្រូវឱ្យបានមុន

- ត្រូវធ្វើការត្រួតពិនិត្យ ការទំនាក់ទំនងតាមទូរសព្ទ័មុនថ្ងៃ ចូលរួមកម្មវិធី
- គ្រប់អង្គការដៃគូរ គួរតែមកតាមការអញ្ជើញរបស់អង្គការអាក់សិនអេត
- អង្គការដៃគូត្រូវតែរបាយការណ៌និង ផែនការច្បាស់លាស់
- រៀបចំផែនការច្បាស់លាស់-កំណត់ពេលវេលា–ចេះតាមដាន និងវាយតំលៃការងារដែលគួរធ្វើឱ្យប្រសើឡើង
- ត្រូវយកចិត្តទុកដាក់ក្នុងការងារដែលបានធ្វើកន្លងមក
- យលទៅផ្សព្វផ្សាយដល់ក្រុមគោលដៅបន្ត និង ឱ្យក្រុមគោលដៅចេះប្រើប្រាស់ជីធម្មជាតិ ។

- **យោបល់ផ្សេងៗ**

- សំរបសំរួលចែករង្វាន់អ្នកចូលរួម ដូចជាសៀវភៅ ប៊ិច
- សុំធ្វើយ៉ាងណា ពេលក្រោយយកកសិករទៅបង្រៀនកសិករ តែខ្លួនឯងមិនចេះ ។
- សូមអ្នកពាក់ពន្ធ័ក្នុងក្រុមបណ្តាញ ធ្វើការទំនាក់ទំនង និង ចែករំលែកបន្តការងារ
- វគ្គគួររៀបចំឱ្យមានរយៈពេលវែងជាងថ្ងៃនេះ ដើម្បីយកចំណេះដឹងថ្មីៗមកចែករំលែកដល់សមជិកបណ្តាញ
- ការសំរបសំរួលគួរតែឱ្យបានទាន់ពេលវេលា
- ក្រុមស្នូលចែករំលែកផែនការយុទ្ធសាស្ត្រច្បាស់លាស់ ក្នុងបេសកកម្មរបស់ខ្លួន
- សំណូមពរឱ្យអង្គការអាក់សិនអេត ឆ្នាំ២០១១ជួយពង្រឹងបណ្តាញឱ្យរឹងមាំថែមទៀត
- សូមឱ្យមានវគ្គឆ្លុះបញ្ចាំង ១ឆ្នាំឱ្យបានពីរដង
- អង្គការអាក់សិនអេត គួរតែផ្តល់ការបើកវគ្គសិក្ខាសាលាផ្សេងៗ ដែលពាក់ពន្ធ័នឹងបច្ចេកទេសផ្សេងៗ ដើម្បី
- ឱ្យមានប្រសិទ្ធិភាពក្នុងការដឹកនាំ ឬគ្រប់គ្រងការងារនៅក្នុងសហគមន៍ ។
- គួរតែសិក្ខាសាលាលើកក្រោយទៅធ្វើនៅ ខេត្តរតនៈគីរី

–សមាជិក CFSNC មាន១៥អង្គការ

សិក្ខាកសាលា នេះបានបញ្ចប់សព្វគ្រប់នៅវេលាម៉ោង ០៦.០០ ក្រោមបរិយាកាសរីករាយក្រៃលែង

ស្វាយរៀង ថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ ២០១០

អ្នកធ្វើកំណត់ហេតុ